ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.[illegible]

# ប្រកាសអន្តរក្រសួង
## ស្ដីពី
## ការដាក់ពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/0១០៥/ ០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/ ០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/ ០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការងារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia

ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០២០ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣៩ និងមាត្រា១៤៤ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១០ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨៧ ចំណងជើងចំណុច “គ” ផ្នែកទី៣ នៃជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារ ដែលត្រូវប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពីការងារ ដែលត្រូវប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣២៦/២២ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីប្រាក់ឈ្នួលយោងប្រចាំថ្ងៃ
- បានឃើញសារាចរលេខ០០៦ សហវ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវានិងចំណូលពីការពិន័យជាប្រាក់ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## **សម្រេច**

**ប្រការ១ .-**

ការផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាសមត្ថកិច្ចរបស់អធិការការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ២ .-**

ការផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវបានរៀបចំជាបញ្ជីផាកពិន័យ ដែលមានរាយលម្អិតអំពីប្រភេទបទល្មើស ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ចំនួនថ្ងៃផាកពិន័យ និងកម្រិតទឹកប្រាក់ផាកពិន័យទៅតាមស្ថានទម្ងន់នៃប្រភេទបទល្មើសនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃប្រកាសអន្តរក្រសួងនេះ។

ក្នុងករណីបុគ្គលប្រព្រឹត្តល្មើសមិនព្រមបង់ប្រាក់ផាកពិន័យតាមការកំណត់ អធិការការងារនឹងកសាងសំណុំរឿងបញ្ជូនទៅសាលាជម្រះក្តីមានសមត្ថកិច្ច ស្របតាមនីតិវិធីច្បាប់ជាធរមាន។

**ប្រការ៣ .-**

ចំណូលប្រមូលបានពីការផាកពិន័យ និងការផ្តន្ទាទោសពិន័យជាប្រាក់ ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវកត់ត្រាជាចំណូលថវិការបស់រដ្ឋបាលថ្នាក់ជាតិ។

ចំណូលប្រមូលបានពីការផាកពិន័យ និងការផ្តន្ទាទោសពិន័យជាប្រាក់ ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវកត់ត្រាជាចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត ដែលជាចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ៤ .-**

នីតិវិធីនៃការផាកពិន័យលើប្រភេទបទល្មើសដែលចែងក្នុងប្រការ២ នៃប្រកាសអន្តរក្រសួងនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ៥ .-**

ប្រកាសរួមលេខ៦៥៩ សហវ.ប្រក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៤ កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងលេខ.[illegible]............ សហវ.ប្រក.អទច ចុះថ្ងៃទី..[illegible]..... ខែ[illegible].. ឆ្នាំ២០២៣ ស្តីពីការផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

**បញ្ជីផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ**

| លេខរៀង បទល្មើស | បរិយាយ | មាត្រា នៃច្បាប់ | ប្រាក់ឈ្នួល យោងប្រចាំថ្ងៃ (រៀល/ថ្ងៃ) | ចំនួនថ្ងៃ ផាកពិន័យ (ថ្ងៃ) | ទឹកប្រាក់ ផាកពិន័យ (រៀល) |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ = ៤ x ៥ |
| ១ | ការរើសអើង | មាត្រា១២ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ២ | គ្មានច្បាប់ស្តីពីការងារតម្កល់នៅសហគ្រាសគ្រឹះស្ថាន | មាត្រា១៤ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ៣ | ការងារដោយបង្ខំ | មាត្រា១៥ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៤ | ការជួលមនុស្សឱ្យធ្វើការងារដើម្បីកាត់ប្រាក់ជំពាក់ | មាត្រា១៦ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៥ | គ្មានសេចក្តីប្រកាសជូនដំណឹងបើក ឬបិទសហគ្រាសគ្រឹះស្ថាន | មាត្រា១៧<br>មាត្រា១៨ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៦ | គ្មានសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | មាត្រា២០ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ៧ | គ្មានសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក | មាត្រា២១ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៨ | គ្មានបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស | មាត្រា២២ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ៩ | មិនបានរៀបចំបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសក្នុងរយៈពេលបីខែបន្ទាប់ពីថ្ងៃបើកសហគ្រាស ឬបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសដែលដាក់ឱ្យប្រើប្រាស់គ្មានទិដ្ឋាការរបស់អធិការការងារ | មាត្រា២៤ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ១០ | និយោជកពិន័យជាប្រាក់ចំពោះកម្មករនិយោជិតដោយកាត់បន្ថយប្រាក់ឈ្នួល ដែលត្រូវទទួលបានជាធម្មតា | មាត្រា២៨ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ១១ | មិនបានបិទផ្សាយបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសនៅទីកន្លែង ដែលកម្មករនិយោជិតងាយមើល | មាត្រា២៩ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ១២ | កែប្រែបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសដោយមិនគោរពតាមលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលនៅជាធរមាន | មាត្រា៣០ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |

| លេខរៀងបទល្មើស | បរិយាយ | មាត្រានៃច្បាប់ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល/ថ្ងៃ) | ចំនួនថ្ងៃជាកពិន័យ (ថ្ងៃ) | ទឹកប្រាក់ជាកពិន័យ (រៀល) |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ = ៤ x ៥ |
| ១៣ | ការប្រើប្រាស់សៀវភៅការងារកម្មករនិយោជិតខ្មែរខុសគោលការណ៍ច្បាប់ | មាត្រា៣៤ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ១៤ | មិនចុះទិដ្ឋាការចូល ឬឈប់ធ្វើការនៅក្នុងសៀវភៅការងារកម្មករនិយោជិតខ្មែរ | មាត្រា៣៧ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ១៥ | គ្មានសៀវភៅបើកប្រាក់ | មាត្រា៣៩ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ១៦ | អាគារូបដ្ឋានដែលបើកលក់ មិនបានអនុវត្តតាមគ្រប់លក្ខខណ្ឌដែលបានកំណត់ | មាត្រា៤២ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ១៧ | ការបើកអាគារូបដ្ឋាន មិនគោរពតាមប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មាត្រា៤៣ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ១៨ | និយោជកតម្រូវឱ្យមានកិច្ចធានាជាប្រាក់កាស ឬជាបណ្ណសិទ្ធិណាមួយក្នុងការចុះកិច្ចសន្យាការងារ ឬការរក្សាកិច្ចសន្យាការងារ | មាត្រា៤៤ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ១៩ | គ្មានកិច្ចសន្យាការិយភារីជាលាយលក្ខណ៍អក្សរ | មាត្រា៤៥ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ២០ | កេងប្រយោជន៍ដោយការិយភារី | មាត្រា៤៦ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ២១ | ការិយភារីមិនបានបិទប្រកាសឋានៈ នាម អាសយដ្ឋាននៃសហគ្រិន | មាត្រា៤៩ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ២២ | សហគ្រិនមិនបានបញ្ជូនបញ្ជីរាយនាមការិយភារីដែលបានចុះកិច្ចសន្យាជាមួយទៅអធិការដ្ឋានការងារ | មាត្រា៥០ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ២៣ | គ្មានការហ្វឹកហ្វឺនកូនជាង ឬមានកូនជាងមិនគ្រប់ចំនួនតាមអត្រាកំណត់ | មាត្រា៥៧ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ២៤ | គ្មានការបំពេញកាតព្វកិច្ចរបស់គ្រូក្នុងការបង្រៀន សម្រួលដល់កូនជាង និងពុំមានចេញវិញ្ញាបនបត្រ | មាត្រា៥៩ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ២៥ | អនុវត្តមិនត្រឹមត្រូវតាមនីតិវិធីនៃការព្យួរកិច្ចសន្យាការងារ | មាត្រា៧២ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ២៦ | មិនព្រមចេញវិញ្ញាបនបត្របញ្ជាក់ការងារនៅពេលផ្តាច់កិច្ចសន្យាការងារ | មាត្រា៩៣ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ២៧ | ការបញ្ឈប់ពីការងាររួមគ្នាមិនប្រតិបត្តិតាមនីតិវិធីជាធរមាន | មាត្រា៩៥ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ២៨ | ផ្តល់ប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតមិនបានត្រឹមត្រូវ | មាត្រា១០៤ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |

| លេខរៀង បទល្មើស | បរិយាយ | មាត្រា នៃច្បាប់ | ប្រាក់ឈ្នួល យោងប្រចាំថ្ងៃ (រៀល/ថ្ងៃ) | ចំនួនថ្ងៃ ផាកពិន័យ (ថ្ងៃ) | ទឹកប្រាក់ ផាកពិន័យ (រៀល) |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ = ៤ x ៥ |
| ២៩ | ផ្តល់ប្រាក់ឈ្នួលមិនស្មើគ្នា ចំពោះការងារដែលមានលក្ខខណ្ឌដូចគ្នា និងផលដែលធ្វើបានស្មើគ្នា | មាត្រា១០៦ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៣០ | មិនជូនដំណឹងដល់កម្មករនិយោជិតអំពីលក្ខខណ្ឌប្រាក់ឈ្នួល និងរយៈពេលបើកប្រាក់ឈ្នួល | មាត្រា១១២ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ៣១ | មិនបើកប្រាក់ឈ្នួលដោយផ្ទាល់ដៃ ឬបើកប្រាក់ឈ្នួលតាមវិធីផ្សេងដោយគ្មានការយល់ព្រមពីកម្មករនិយោជិត | មាត្រា១១៣ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៣២ | បន្ថយសេរីភាពកម្មករនិយោជិត ក្នុងការប្រើប្រាស់ប្រាក់ឈ្នួលរបស់ខ្លួន | មាត្រា១១៤ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៣៣ | បើកប្រាក់ឈ្នួលជូនកម្មករនិយោជិតមិនបានត្រឹមត្រូវ ឬធ្វើនៅទីកន្លែងហាមឃាត់ ឬពេលវេលាមិនសមស្រប | មាត្រា១១៥ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៣៤ | បើកប្រាក់ឈ្នួលជូនកម្មករនិយោជិតហួសរយៈពេលកំណត់ ឬមិនគោរពតាមចំនួនលើកដែលបានកំណត់ | មាត្រា១១៦ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៣៥ | ការកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ក្នុងគោលបំណងឱ្យអ្នកទទួលរកការឱ្យធ្វើ ដោយចំពោះ ឬមិនចំពោះ | មាត្រា១២៦ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៣៦ | ការកាត់ប្រាក់ឈ្នួលទូទាត់សំណង ប៉ះពាល់ដល់បរិមាណភាគជាចាំបាច់សម្រាប់ការចិញ្ចឹមជីវិតនៃកម្មករនិយោជិត និងគ្រួសារ | មាត្រា១២៧ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៣៧ | ការកាត់ទុកប្រាក់រំលស់ និងប្រាក់ឈ្នួលខុសនីតិវិធីកំណត់ | មាត្រា១២៨ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៣៨ | ការដកហូត ឬការកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ខុសពីគោលការណ៍ច្បាប់ | មាត្រា១២៩ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៣៩ | មិនបានត្រួតពិនិត្យ និងបើកប្រាក់ធានានុគ្រោះឱ្យបានត្រឹមត្រូវ | មាត្រា១៣៤ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ៤០ | តម្រូវឱ្យកម្មករនិយោជិត ធ្វើការលើសចិរវេលាកំណត់ប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ | មាត្រា១៣៧ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៤១ | មិនបានបែងចែកចិរវេលាតាមវគ្គធ្វើការ ឬចែកពេលឱ្យធ្វើការប្រចាំថ្ងៃលើសពីពីរវគ្គ | មាត្រា១៣៨ ថ្មី | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៤២ | ផ្តល់ប្រាក់ឈ្នួលធ្វើការថែមម៉ោងជូនកម្មករនិយោជិតមិនបានត្រឹមត្រូវ | មាត្រា១៣៩ ថ្មី | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៤៣ | បង្ខំឱ្យធ្វើការសង ឬកំណត់ចិរវេលាធ្វើការសង ឬការពន្យារចិរវេលាធ្វើការ ខុសពីគោលការណ៍កំណត់ | មាត្រា១៤០ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៤៤ | អនុវត្តមិនបានត្រឹមត្រូវតាមចិរវេលាធ្វើការងារដែលបានកំណត់ | មាត្រា១៤១ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |

| លេខរៀងបទល្មើស | បរិយាយ | មាត្រានៃច្បាប់ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល/ថ្ងៃ) | ចំនួនថ្ងៃជាកពិន័យ (ថ្ងៃ) | ទឹកប្រាក់ជាកពិន័យ (រៀល) |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ = ៤x ៥ |
| ៤៥ | ការកំណត់ចិរវេលា និងអត្រាប្រាក់ឈ្នួលការងារពេលយប់មិនបានត្រឹមត្រូវ | មាត្រា១៤៤ ថ្មី | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៤៦ | និយោជកមិនបានគោរពនូវលក្ខខណ្ឌនៃការធ្វើការនៅថ្ងៃឈប់បុណ្យដូចជា គ្មានលិខិតអនុញ្ញាតពីអធិការការងារ ឬឱ្យកម្មករនិយោជិតធ្វើការនៅថ្ងៃឈប់បុណ្យលើសពីការអនុញ្ញាតពីអធិការការងារ ឬមិនផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត | មាត្រា១៦២ថ្មី | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៤៧ | មិនបានផ្តល់ប្រាក់បំណាច់ស្មើនឹងប្រាក់ឈ្នួល ចំពោះថ្ងៃឈប់សម្រាកបុណ្យ | មាត្រា១៦៣ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៤៨ | មិនបានផ្តល់ប្រាក់បំណាច់នៃការងារដែលបានធ្វើក្នុងឱកាសថ្ងៃឈប់បុណ្យបន្ថែមលើប្រាក់ឈ្នួល | មាត្រា១៦៤ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៤៩ | មិនបានផ្តល់ការឈប់សម្រាកប្រចាំឆ្នាំ | មាត្រា១៦៦ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៥០ | ទូទាត់ជាប្រាក់ជំនួសឱ្យការមិនឈប់សម្រាកប្រចាំឆ្នាំ | មាត្រា១៦៧ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៥១ | មិនបានផ្តល់ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំមុនថ្ងៃឈប់សម្រាកប្រចាំឆ្នាំ | មាត្រា១៦៨ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៥២ | មិនបានគណនាថ្ងៃឈប់សម្រាកប្រចាំឆ្នាំ | មាត្រា១៦៩ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៥៣ | មិនអនុវត្តតាមនីតិវិធីនៃការឈប់សម្រាកប្រចាំឆ្នាំ | មាត្រា១៧០ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៥៤ | អនុវត្តមិនត្រឹមត្រូវតាមការកំណត់ប្រភេទការងារដែលបង្កគ្រោះថ្នាក់ ឬលើសកម្លាំងសម្រាប់ក្មេងមានអាយុតិចជាង១៨ឆ្នាំ | មាត្រា១៧៣ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៥៥ | ប្រើប្រាស់អនីតិជនដែលមានអាយុតិចជាង១៨ឆ្នាំ ធ្វើការនៅ អណ្តូងរ៉ែ ឬការយករ៉ែ ឬយកថ្មក្នុងដី និងមិនបានអនុវត្តតាមប្រកាសដែលកំណត់លក្ខខណ្ឌពិសេសនៃការងារ និងការហ្វឹកហ្វឺនវិជ្ជាជីវៈដល់អនីតិជនដែលធ្វើការក្រោមដី | មាត្រា១៧៤ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៥៦ | មិនត្រូវផ្តល់ការងារពេលយប់ដល់ក្មេងដែលមានអាយុតិចជាង ១៨ឆ្នាំ | មាត្រា១៧៥ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៥៧ | ផ្តល់ការឈប់សម្រាកពេលយប់សម្រាប់ក្មេងមិនបានត្រឹមត្រូវតាមចិរវេលាកំណត់ | មាត្រា១៧៦ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៥៨ | ប្រើប្រាស់កម្មករនិយោជិតវ័យក្មេងមិនបានត្រឹមត្រូវទៅតាមការកំណត់ | មាត្រា១៧៧ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៥៩ | ប្រើប្រាស់កម្មករនិយោជិតវ័យក្មេងឱ្យធ្វើការងារលើសកម្លាំង | មាត្រា១៧៨ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |

| លេខរៀងបទល្មើស | បរិយាយ | មាត្រានៃច្បាប់ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល/ថ្ងៃ) | ចំនួនថ្ងៃជាកពិន័យ (ថ្ងៃ) | ទឹកប្រាក់ជាកពិន័យ (រៀល) |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ = ៤ x ៥ |
| ៦០ | មិនមានសៀវភៅបញ្ជីចុះនាមក្មេងអាយុតិចជាង១៨ឆ្នាំ | មាត្រា១៧៩ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៦១ | មិនមានសៀវភៅបញ្ជីចុះនាមក្មេងអាយុតិចជាង១៨ឆ្នាំ | មាត្រា១៨០ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៦២ | អនុវត្តមិនត្រឹមត្រូវចំពោះការឈប់សម្រាលកូន | មាត្រា១៨២ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៦៣ | មិនផ្តល់ពេលវេលាឱ្យបំបៅកូនក្នុងពេលម៉ោងធ្វើការ | មាត្រា១៨៤ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៦៤ | គ្មានបន្ទប់បំបៅកូន និងទារកដ្ឋាន | មាត្រា១៨៧ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ៦៥ | មិនកំណត់ថិរវេលាធ្វើការសម្រាប់ការងារចម្ការឱ្យបានត្រឹមត្រូវ | មាត្រា១៩៤ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៦៦ | បង្ខំឱ្យកម្មករនិយោជិត ទទួលយកភាគឈ្នួលជាវត្ថុ | មាត្រា១៩៨ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៦៧ | មិនផ្តល់វត្ថុដល់គ្រួសាររបស់កម្មករនិយោជិត ដែលធ្វើការទៀងទាត់ក្នុងចម្ការ | មាត្រា២០០ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៦៨ | គ្មានគេហដ្ឋានសម្រាប់កម្មករនិយោជិតដែលធ្វើការក្នុងចម្ការ | មាត្រា២០៤ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៦៩ | ផ្តល់គេហដ្ឋានមានទំហំតូចជាងទំហំអប្បបរមាសម្រាប់កម្មករនិយោជិត ដែលធ្វើការក្នុងចម្ការ | មាត្រា២០៥ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៧០ | ការសង់គេហដ្ឋានមិនត្រឹមត្រូវតាមបទបញ្ញាអនាម័យ និងសុខភាពសាធារណៈដែលបានកំណត់ | មាត្រា២០៦ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៧១ | មិនផ្តល់ទឹកឱ្យប្រើប្រាស់តាមតម្រូវការជូនកម្មករនិយោជិត ដែលធ្វើការងារចម្ការ | មាត្រា២១០ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៧២ | ធ្វើបង្គន់អនាម័យមានចំនួនមិនសមស្រប និងមិនត្រឹមត្រូវតាមបទដ្ឋានដែលបានកំណត់ | មាត្រា២១៤ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ៧៣ | គ្មានសាលាបឋមសិក្សាសម្រាប់ក្មេងរៀនតាមអត្រាកំណត់ "ការងារចម្ការ" | មាត្រា២២២ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ៧៤ | ពុំបានអនុវត្តតាមលក្ខខណ្ឌអនាម័យ និងសន្តិសុខរបស់កម្មករនិយោជិត ដែលកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មាត្រា២២៩<br>មាត្រា២៣០<br>មាត្រា២៣១ | ៨០ ០០០ | ៨៤ | ៦ ៧២០ ០០០ |

| លេខរៀង បទល្មើស | បរិយាយ | មាត្រា នៃច្បាប់ | ប្រាក់ឈ្នួល យោងប្រចាំថ្ងៃ (រៀល/ថ្ងៃ) | ចំនួនថ្ងៃ ផាកពិន័យ (ថ្ងៃ) | ទឹកប្រាក់ ផាកពិន័យ (រៀល) |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ = ៤ x ៥ |
| ៧៥ | ពុំមានគិលានដ្ឋាន និងក្រុមពេទ្យការងារសម្រាប់ការព្យាបាលបឋម និងការពិនិត្យកាយសម្បទា រើសបុគ្គលិកថ្មី ឬជ្រើសរើសយកឱ្យធ្វើការឡើងវិញ | មាត្រា២៤០<br>មាត្រា២៤១<br>មាត្រា២៤២<br>មាត្រា២៤៣<br>មាត្រា២៤៤<br>មាត្រា២៤៥<br>មាត្រា២៤៦<br>មាត្រា២៤៧ | ៨០ ០០០ | ២៥២ | ២០ ១៦០ ០០០ |
| ៧៦ | មិនទទួលខុសត្រូវលើគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត | មាត្រា២៤៩ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៧៧ | មិនផ្តល់ ឬផ្តល់យឺតយ៉ាវនូវប្រាក់បំណាច់ ឬប្រាក់បំណាច់បន្ថែមជូនកម្មករនិយោជិត ដែលមានគ្រោះថ្នាក់ស្លាប់ ឬបាត់បង់សមត្ថភាពពលកម្មជាអចិន្ត្រៃយ៍ | មាត្រា២៥៣ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ៧៨ | មិនអនុវត្តតាមការព្រមព្រៀងរវាងគូភាគីក្នុងករណីអ្នករងគ្រោះថ្នាក់ការងារអាចនឹងទទួលបានផលប្រយោជន៍ប្រសើរជាង | មាត្រា២៥៥ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ៧៩ | បុគ្គលិកនៅការិយាល័យរកការងារឱ្យធ្វើ តម្រូវឱ្យអ្នកសុំការងារធ្វើបង់កម្រៃ | មាត្រា២៦០ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៨០ | ការបំបិទសិទ្ធិបង្កើតអង្គការវិជ្ជាជីវៈ និងការបង្កើតសហជីព ឬសមាគមទាំងឡាយដែលរួមបញ្ចូលនិយោជក និងកម្មករនិយោជិតទៅក្នុងសហជីព ឬសមាគមតែមួយជាមួយគ្នា | មាត្រា២៦៦ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៨១ | រារាំង ឬហាមឃាត់ចំពោះការបង្កើតសហជីពកម្មករនិយោជិត ឬសមាគមនិយោជក និងការតាក់តែងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរដ្ឋបាល, ការបោះឆ្នោតជ្រើសរើសតំណាងដោយសេរី និងការរៀបចំកម្មវិធីការងាររបស់ខ្លួន | មាត្រា២៦៧ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |

| លេខរៀងបទល្មើស | បរិយាយ | មាត្រានៃច្បាប់ | ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ (រៀល/ថ្ងៃ) | ចំនួនថ្ងៃជាកពិន័យ (ថ្ងៃ) | ទឹកប្រាក់ជាកពិន័យ (រៀល) |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ = ៤ × ៥ |
| ៨២ | អង្គការវិជ្ជាជីវៈដែលបានចុះបញ្ជិការួចហើយ មិនបានចម្លងលក្ខន្តិកៈ និងបញ្ជីរាយនាមអ្នកទទួលខុសត្រូវដឹកនាំ និងកិច្ចការរដ្ឋបាលជូនទៅអធិការដ្ឋានការងារ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ | មាត្រា២៦៨ | ៨០ ០០០ | ៨៤ | ៦ ៧២០ ០០០ |
| ៨៣ | ការកំណត់លក្ខខណ្ឌរបស់ថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈមិនត្រឹមត្រូវ | មាត្រា២៦៩ | ៨០ ០០០ | ៨៤ | ៦ ៧២០ ០០០ |
| ៨៤ | ការកំណត់លក្ខខណ្ឌរបស់ថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈជាជនបរទេសមិនត្រឹមត្រូវ | មាត្រា២៧០ | ៨០ ០០០ | ៨៤ | ៦ ៧២០ ០០០ |
| ៨៥ | រារាំងបំបិទសិទ្ធិសេរីភាពក្នុងការចូលរួម ឬដកខ្លួនចេញពីអង្គការវិជ្ជាជីវៈ | មាត្រា២៧៣ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៨៦ | មិនបានចាត់តាំងប្រតិភូសហជីព | មាត្រា២៧៨ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៨៧ | និយោជកយកការចូលរួមជាសមាជិករបស់សហជីព ឬការចូលរួមក្នុងសកម្មភាពរបស់សហជីព ដើម្បីធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសឱ្យចូលធ្វើការងារ ការដឹកនាំ និងការបែងចែកការងារ ការដំឡើងថ្នាក់ ការផ្ដល់ប្រាក់ឈ្នួល និងការផ្ដល់ផលប្រយោជន៍ វិធានការដាក់វិន័យ និងការបណ្ដេញចេញ | មាត្រា២៧៩ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៨៨ | និយោជកប្រព្រឹត្តអំពើជ្រៀតជ្រែកលើសហជីពកម្មករនិយោជិត | មាត្រា២៨០ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៨៩ | និយោជកកាត់ប្រាក់ឈ្នួលដើម្បីបង់ភាគទានសហជីព ឬបង់ប្រាក់ភាគទានជំនួសកម្មករនិយោជិត | មាត្រា២៨១ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៩០ | មិនបានផ្ដល់សិទ្ធិប្រយោជន៍ជូនប្រតិភូសហជីព ឬអតីតប្រតិភូសហជីព ដែលបានចាកចេញពីតំណែង ឬផ្លាស់ប្ដូរមុខងារ | មាត្រា២៨២ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៩១ | មិនបានបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ឬការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកមិនបានប្រព្រឹត្តទៅតាមនីតិវិធីកំណត់ | មាត្រា២៨៣ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៩២ | ដកហូតសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោតប្រតិភូបុគ្គលិក | មាត្រា២៨៦ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៩៣ | ការរៀបចំជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយមិនត្រឹមត្រូវតាមនីតិវិធីកំណត់ | មាត្រា២៨៧ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៩៤ | មិនទទួលស្គាល់ប្រតិភូជំនួយដែលមានលក្ខណសម្បត្តិជំនួសឱ្យប្រតិភូពេញសិទ្ធិដែលឈប់ពីមុខងារ ឬអវត្តមានមួយរយៈពេល | មាត្រា២៩១ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៩៥ | មិនបានរៀបចំការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកអាណត្តិបន្ត | មាត្រា២៩២ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |

| លេខរៀង បទល្មើស | បរិយាយ | មាត្រា នៃច្បាប់ | ប្រាក់ឈ្នួល យោងប្រចាំថ្ងៃ (រៀល/ថ្ងៃ) | ចំនួនថ្ងៃ ផាកពិន័យ (ថ្ងៃ) | ទឹកប្រាក់ ផាកពិន័យ (រៀល) |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ = ៤ x ៥ |
| ៩៦ | និយោជកមិនបានធ្វើកំណត់ហេតុបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកជូនទៅអធិការដ្ឋានការងារក្នុងរយៈពេលប្រាំបីថ្ងៃ បន្ទាប់ពីការបោះឆ្នោត និងមិនបានបិទកំណត់ហេតុ ដើម្បីផ្សព្វផ្សាយដំណឹងក្នុងសហគ្រាស | មាត្រា២៩៦ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៩៧ | មិនបានចូលរួមផ្សះផ្សាវិវាទការងាររួម | មាត្រា៣០៦ | ៨០ ០០០ | ៤២ | ៣ ៣៦០ ០០០ |
| ៩៨ | មិនបានការពារសេរីភាពរបស់កម្មករនិយោជិតដែលមិនមែនជាកូដករ | មាត្រា៣៣១ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ៩៩ | ការដាក់ទណ្ឌកម្មចំពោះកូដករ | មាត្រា៣៣៣ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ១០០ | ការជ្រើសរើសកម្មករនិយោជិតផ្សេងមកជំនួសកូដករក្នុងអំឡុងពេលធ្វើកូដកម្ម | មាត្រា៣៣៤ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ១០១ | ឡុកអៅមិនស្របតាមនីតិវិធី | មាត្រា៣៣៥ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ១០២ | និយោជកដែលបំបាត់ ឬព្យួរទុកការឈប់សម្រាកប្រចាំសប្តាហ៍របស់កម្មករនិយោជិត ឬក៏ផ្តល់ការសម្រាកនេះផ្ទុយពីបទប្បញ្ញត្តិ ផ្នែកទី៤ ជំពូកទី៦ នៃច្បាប់ការងារ ឬនៃប្រកាសណែនាំអនុវត្តច្បាប់នេះ | មាត្រា៣៦២ | ៨០ ០០០ | ២១ | ១ ៦៨០ ០០០ |
| ១០៣ | អ្នកដឹកនាំ ឬអភិបាលនៃអង្គការវិជ្ជាជីវៈ ដែលនាំអង្គការទាំងនោះឱ្យធ្វើសកម្មភាពផ្ទុយពីគោលដៅ | មាត្រា៣៧៨ | ៨០ ០០០ | ៦៣ | ៥ ០៤០ ០០០ |
| ១០៤ | ជនដែលជំទាស់ ឬប៉ុនប៉ងជំទាស់នឹងការអនុវត្តតាមមុខងារ ឬការប្រើប្រាស់អំណាចដែលប្រគល់ឱ្យអធិការការងារ ឬអភិបាលការងារ ព្រមទាំងអធិការពេទ្យការងារ | មាត្រា៣៨២ | ៨០ ០០០ | ២៥២ | ២០ ១៦០ ០០០ |
| ១០៥ | ជនបរទេសប្រកបមុខរបរណាមួយដោយគ្មានបណ្ណការងារ/សៀវភៅការងារ រួមទាំងបុគ្គលស្វ័យនិយោជន៍ | មាត្រា២៦១<br>មាត្រា៣៨២ | ២០០ ០០០ | ២៥២ | ៥០ ៤០០ ០០០ |
| ១០៦ | គ្មានលិខិតអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស រួមទាំងបុគ្គលស្វ័យនិយោជន៍ | មាត្រា២៦៤ | ២០០ ០០០ | ៦៣ | ១២ ៦០០ ០០០ |
| ១០៧ | ប្រើប្រាស់ហត្ថពលកម្មបរទេសគ្មានសៀវភៅការងារ | មាត្រា៣៧២ | ២០០ ០០០ | ៦៣ | ១២ ៦០០ ០០០ |